# របៀបកំណត់សិទ្ធិរបស់កម្មវិធីនៅលើទូរស័ព្ទ Android

**ធ្វើបច្ចុប្បន្នភាពចុងក្រោយ: 22-03-2021**

អ្នកប្រើប្រាស់ទូរស័ព្ទមួយចំនួនប្រហែលជាមិនចាប់អារម្មណ៍ទេថា នៅពេលដែលពួកគេតម្លើងកម្មវិធីណាមួយចូលទៅក្នុងទូរស័ព្ទ កម្មវិធីនោះតម្រូវឱ្យពួកគេយល់ព្រមផ្តល់សិទ្ធិ ក្នុងការចូលទៅប្រើទិន្នន័យ ឬមុខងារមួយចំនួននៅក្នុងទូរស័ព្ទដៃនោះ ដែលការទាមទារចូលទៅប្រើទិន្នន័យ ឬមុខងារមួយចំនួន ហាក់ដូចជាមិនចាំបាច់ ឬមិនទាក់ទងនឹងការដំណើរការរបស់កម្មវិធីនោះទេ។

ឧទាហរណ៍៖ កម្មវិធី Google Map អាចទាមទារសិទ្ធិក្នុងការប្រើមុខងារ GPS ឬទីតាំងនៅក្នុងទូរស័ព្ទរបស់អ្នកដើម្បីឱ្យអ្នកអាចប្រើផែនទីបាន តែហាក់ដូចជាមិនចាំបាច់ចូលទៅប្រើទិន្នន័យបញ្ជីលេខទូរស័ព្ទ(Contacts) ឬមុខងារកាមេរ៉ាទេ។ កម្មវិធីប្រជុំតាមអនឡាញ Zoom អាចត្រូវការសិទ្ធិក្នុងការប្រើ Microphone និង កាមេរ៉ា ដើម្បីឱ្យអ្នកអាចធ្វើការខលវីឌីអូបាន តែហាក់ដូចជាមិនចាំបាច់ទាមទារប្រើមុខងារ GPS នោះទេ។ល។

ការស្នើសុំចូលទៅប្រើទិន្នន័យ និងប្រើមុខងារដែលមិនចាំបាច់ ឬមិនទាក់ទងនឹងការដំណើរការកម្មវិធីអាចអនុញ្ញាតឱ្យកម្មវិធីនោះប្រមូលយកទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកទៅប្រើក្នុងគោលបំណងផ្សេងៗ ដូចជា យកទៅធ្វើការវិភាគពីអ្នកប្រើប្រាស់ ដើម្បីធ្វើទីផ្សារ លក់ទិន្នន័យដែលទាក់ទងទៅឱ្យក្រុមហ៊ុនផ្សេង ឬជនទីបីជាដើម ដែលនេះជាការរំលោភលើសិទ្ធិឯកជនភាពរបស់អ្នកប្រើប្រាស់។

ទោះបីជាយ៉ាងណាក៏ដោយ Android អាចអនុញ្ញាតឱ្យអ្នកប្រើប្រាស់ចូលទៅត្រួតពិនិត្យ ផ្លាស់ប្តូរ ឬបិទមុខងារណាដែលមិនចាំបាច់ ចេញពីកម្មវិធី ទាំងនោះបាន ដោយអនុវត្តតាមវិធីដូចខាងក្រោម៖

*សម្គាល់: ទូស័ព្ទដែលប្រើប្រព័ន្ធប្រតិបត្តិការរបស់ Android មានច្រើនប្រភេទ នោះការចូលទៅកាន់ការកំណត់ផ្សេងៗអាចខុសៗគ្នាតាមប្រភេទទូសព្ទនិមួយៗ។*

**ជំហានទី១៖** ចូលទៅកាន់កម្មវិធីណាមួយក្នុងទូរស័ព្ទរបស់អ្នក (ឧ. Drive) → ចុចលើកម្មវិធីនោះឱ្យជាប់



**ជំហានទី២៖** ចុចលើនិមិត្តសញ្ញា App info




**ជំហានទី៣៖** ចុចលើពាក្យ Permissions

បន្ទាប់មកអ្នកនឹងឃើញថា កម្មវិធីនោះមានសិទ្ធិចូលទៅប្រើទិន្នន័យ ឬមុខងារណាខ្លះក្នុងទូរស័ព្ទរបស់អ្នក។ មុខងារខ្លះគឺជាតម្រូវការចាំបាច់ដើម្បីអាចឱ្យកម្មវិធីអាចដំណើរការបាន ប្រសិនបើអ្នកបិទមុខងារដែលចាំបាច់នោះ កម្មវិធីអាចដំណើរការមិនរលូន ឬអាចមិនដំណើរការតែម្តង។ ដូច្នេះអ្នកត្រូវតែធ្វើការត្រួតពិនិត្យឱ្យបានល្អិតល្អន់។




**ជំហានទី៤៖** ចុចលើមុខងារ (ឧ. Storage)→ ជ្រើសរើស Allow ប្រសិនបើអ្នកអនុញ្ញាតឱ្យកម្មវិធីអាចចូលទៅប្រើទិន្នន័យ ឬមុខងារនោះ ឬក៏ចុច Deny ប្រសិនបើមិនអនុញ្ញាតឱ្យកម្មវិធីមានសិទ្ធិប្រើទិន្នន័យឬមុខងារនោះទេ។




ដើម្បីឱ្យមានសុវត្ថិភាព និងរក្សាបាននូវឯកជនភាពកាន់តែខ្ពស់ សូមធ្វើការត្រួតពិនិត្យគ្រប់កម្មវិធីដែលមាននៅក្នុងទូរស័ព្ទរបស់អ្នក លុបកម្មវិធីដែលមិនប្រើ ឬមិនចាំបាច់ចេញ តម្លើងតែកម្មវិធីដែលមាននៅក្នុង Play Store ត្រួតពិនិត្យ ឬកែប្រែសិទ្ធិនៃការចូលទៅប្រើមុខងារ ឬទិន្នន័យនៅក្នុងទូរស័ព្ទ និងជាពិសេសត្រូវធ្វើបច្ចុប្បន្នភាពកម្មវិធីទាំងអស់ឱ្យបានជាប្រចាំ។

ប្រភព:

https://guidebooks.google.com/android/changesettingspermissions/changeyourapppermissions